**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខ: ០៦៦៦ សហវ.អគពដ

រាជធានីភ្នំពេញ, ថ្ងៃទី ០៩ ខែ សីហា ឆ្នាំ២០១២

# សេចក្តីជូនដំណឹង
## ស្តីពី
## ការដាក់លិខិតប្រកាស និងការបង់ប្រាក់ពន្ធលើអចលនទ្រព្យ

ដើម្បីសម្រួលដល់ការដាក់លិខិតប្រកាស និង ការបង់ប្រាក់ពន្ធលើអចលនទ្រព្យ សម្រាប់ឆ្នាំ២០១២នេះតទៅ ឲ្យកាន់តែមានភាពងាយស្រួល និងឆាប់រហ័ស ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សូមជូនដំណឹងដល់ លោក លោកស្រី ជាម្ចាស់អចលនទ្រព្យ ជ្រាបថា ក្រសួងមានការកែសម្រួលចំពោះនីតិវិធី នៃការបង់ប្រាក់ពន្ធលើអចលនទ្រព្យ ដូចខាងក្រោម ៖

១. ការបំពេញបែបបទទម្រង់អចលនទ្រព្យ ៖

- អចលនទ្រព្យទើបប្រកាសលើកដំបូង ឬអចលនទ្រព្យបានប្រកាសបង់ពន្ធឆ្នាំកន្លងទៅរួចហើយ តែមានការប្រែប្រួល ដូចជា ការប្តូរម្ចាស់អចលនទ្រព្យ ទំហំអចលនទ្រព្យ តម្លៃអចលនទ្រព្យ អត្រាប្តូរប្រាក់ ជាដើម... ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៅតែតម្រូវឲ្យម្ចាស់អចលនទ្រព្យបំពេញទម្រង់ទាំងបីប្រភេទ ដូចតាមការណែនាំក្នុងប្រកាសលេខ ៤៩៣ សហវ.ប្រក ដដែល ដោយម្ចាស់អចលនទ្រព្យអាចទាញយកទម្រង់លិខិតទាំងបីខាងលើនេះ តាមគេហទំព័រ www.tax.gov.kh របស់អគ្គនាយកដ្ឋានពន្ធដារ ដើម្បីប្រើប្រាស់ក្នុងការបំពេញកាតព្វកិច្ចនេះ ។
- ចំពោះអចលនទ្រព្យ ដែលបានបំពេញទម្រង់ទាំងបីខាងលើ និងបានបង់ពន្ធឆ្នាំ២០១១រួចហើយ សម្រាប់ការប្រកាស និងបង់ពន្ធសម្រាប់ឆ្នាំ២០១២តទៅ ពុំចាំបាច់សរសេរបំពេញទម្រង់ដូចអចលនទ្រព្យខាងលើឡើយ ម្ចាស់អចលនទ្រព្យគ្រាន់តែបង្ហាញលេខអត្តសញ្ញាណកម្មអចលនទ្រព្យ ដោយភ្ជាប់មកជាមួយនូវលិខិតប្រកាសបង់ពន្ធឆ្នាំ២០១១ ជូនដល់ភ្នាក់ងារពន្ធដារនៅសាខាពន្ធដារខេត្ត-ខណ្ឌ ដែលអចលនទ្រព្យនោះស្ថិតនៅជាការស្រេច ។ បន្ទាប់មក ភ្នាក់ងារពន្ធដារនឹងបោះពុម្ព (Print) ចេញនូវព័ត៌មានប្រកាសពន្ធជូនដល់ លោក លោកស្រី ដែលជាម្ចាស់អចលនទ្រព្យ ពិនិត្យ និងទទួលស្គាល់ ដើម្បីបង់ប្រាក់ពន្ធ ។

២. ការបង់ពន្ធលើអចលនទ្រព្យ ៖

- ដើម្បីទទួលបានភាពងាយស្រួល ច្បាស់លាស់ និងលឿនជាងមុន អគ្គនាយកដ្ឋានពន្ធដារបានសម្រួលពីការចេញបង្កាន់ដៃទទួលប្រាក់ពន្ធដោយសរសេរផ្ទាល់ដៃមកជាការចេញលិខិតបញ្ជាក់ការបង់ពន្ធដោយប្រព័ន្ធកុំព្យូទ័រវិញ ។
- ការបង់ប្រាក់ពន្ធ និងប្រាក់ពន្ធបន្ថែម ៖
  + ប្រាក់ពន្ធដល់ ១០០,០០០រៀល ម្ចាស់អចលនទ្រព្យអាចបង់នៅបេឡាសាខាពន្ធដារខេត្ត-ខណ្ឌ ឬ នៅតាមប្រព័ន្ធធនាគារ ។
  + ប្រាក់ពន្ធលើស ១០០,០០០រៀល ម្ចាស់អចលនទ្រព្យត្រូវបង់នៅតាមប្រព័ន្ធធនាគារតាមរយៈលិខិតបញ្ជាបង់ប្រាក់របស់សាខាពន្ធដារខេត្ត-ខណ្ឌ ដែលពាក់ព័ន្ធនោះ ។

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានក្តីសង្ឃឹមយ៉ាងមុតមាំថា ការដាក់លិខិតប្រកាស និងការបង់ប្រាក់ពន្ធនេះនឹងបានជួយសម្រួលដល់ លោក លោកស្រី ជាម្ចាស់អចលនទ្រព្យ ឲ្យកាន់តែងាយស្រួល និងកាត់បន្ថយរយៈពេលក្នុងការរង់ចាំបាននៅកម្រិតអប្បរមា ។

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

**គាត ឈន់**

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92, Sangkat Wat Phnom , khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798